# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ វាសនានៃស្ត្រីកម្មករខ្មែរ

website ៖ www.hoksavann.org

ថ្ងៃទី១៨ មេសា ២០០៩



បន្ទាប់ពីបញ្ចប់សង្គ្រាមក្នុងស្រុកមក ប្រជាពលរដ្ឋខ្មែរបានផ្ដើមជីវភាពឡើងវិញ ។ ដោយសារការបើកផ្សារសេរី មានអ្នកវិនិយោគទុនក៏មកបង្កើតរោងចក្រ ជាពិសេសរោងចក្រធ្វើសំលៀកបំពាក់ ។ រោងចក្រទាំងនេះបានទទួលស្ត្រីខ្មែរចំនួនប្រហែល៣សែននាក់ឲ្យចូលធ្វើជាកម្មករ ។ ដូច្នេះរោងចក្របានជួយឲ្យខ្មែរមានការធ្វើរាប់សែននាក់ ។ ឥឡូវនេះ ដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោក រោងចក្រខ្លះបានត្រូវបិទ ធ្វើឲ្យស្ត្រីកម្មករខ្មែរអត់ការងារធ្វើរាប់ម៉ឺននាក់ ទោះបីមានបើករោងចក្រថ្មីៗខ្លះទៀតក៏ដោយ ។ តើស្ត្រីខ្មែរដែលអត់ការងារធ្វើទាំងនោះងាកទៅរកការងារអ្វីធ្វើ ? ។

ការងារមានច្រើនយ៉ាង ចំពោះព្រះពុទ្ធសាសនាបានហាមការងារណាដែលមិនប្រកបដោយធម៌ ដូចជាការជួញដូរមនុស្ស ជួញគ្រឿងអាវុធ ជួញគ្រឿងញៀនគ្រឿងស្រវឹង ជួញថ្នាំពិស និងជំនួញខ្លះទៀត ដែលជាមុខរបរចាត់ចូលក្នុងអបាយមុខ គឺមុខរបរដូចជាស្រីពេស្យាចារ ។ មុខរបរស្រីពេស្យាចារនេះ តាមផ្លូវអាណាចក្រ ក៏សង្គមមនុស្សមិនឲ្យតម្លៃដែរ ។ ប្រទេសភាគច្រើនក្នុងលោកមិនដាក់មុខរបរនេះឲ្យស្របច្បាប់ឡើយ ។ តាមធម្មតាមុខរបរនេះ គេត្រូវការតែវ័យនៅក្មេង លុះដល់ពេលមានចំណាស់បន្តិច គេឈប់ត្រូវការហើយ ។ ជាលទ្ធផលអ្នកប្រកបមុខរបរនេះ អាចកើតរោគអេដ ជារោគគ្មានថ្នាំព្យាបាលជាឡើយ ។ ដូច្នេះស្ត្រីនោះត្រូវពិការរហូតបាត់បង់ជីវិត ។ មុខរបរដែលមិនស្រប

ច្បាប់ ផ្លូវចិត្តតែងតែមានភ័យខ្លាចជានិច្ច ជាមុខរបរល្មួចលោក់ ហើយតែងមាន ការប្រមាថពីបុរស ដើម្បីបង្ខំឲ្យធ្វើតាមបំណងរបស់ខ្លួន ។ មិនតែប៉ុណ្ណោះ មេបនដែលគ្មានធម៌មេត្តា តែងតែកេងប្រវ័ញ្ចនិងធ្វើបាបស្ត្រីបំរើផ្លូវភេទផង ។

ទំនៀមទំលាប់ខ្មែរខាងផ្លូវភេទនេះ មានការលាក់លៀមនិងតឹងតែងណាស់ ។ កុមារីខ្មែរមានវ័យជំទង់ ម្តាយឪពុកតែងតែការពារមិនបណ្តោយឲ្យដើរតែពីរនាក់ជាមួយបុរសណាឡើយ ។ ពេលធំពេញរូបរាងជំនាន់ដើមតែងតែធ្វើពិធីមួយ ហៅថាពិធីចូលម្លប់ ។ ពិធីនេះមានគោលបំណងសំខាន់គឺការអប់រំផ្លូវចិត្ត ពុំមែនបន្ទំពណ៌សម្បុរឲ្យស្អាតដូចអ្នកខ្លះយល់នោះឡើយ ។ ចាស់ពីបូរាណឆ្លាតណាស់ ពេលកូនស្រីគ្រប់ការហើយត្រូវតែប្រយ័ត្ន ព្រោះវ័យនេះ បើមិនបានអប់រំចិត្តឲ្យល្អទេ អាចភ្លើតភ្លើនក្នុងផ្លូវកាមគុណកន្លងប្រពៃណី ។ ក៏ដូចគ្នានឹងកូនប្រុសជំទង់ឲ្យទៅនៅវត្ត ឲ្យបួសជាសាមណេរជាភិក្ខុ ក៏ដើម្បីអប់រំចិត្តឲ្យមានចរិយាល្អដូចកូនស្រីដែរ ។ ចរិយាកូនប្រុសកូនស្រីខ្មែរសម័យដើម មិនដែលខូចកាចនឹងគ្នាឡើយ បើយូរៗមានមួយ ម្តាយឪពុកមានការខ្មាស់គេណាស់ មានខ្លះមិនហ៊ាននៅក្នុងភូមិនោះផង បានផ្លាស់ទៅនៅខេត្តដទៃទៀត ។ ខ្មែរឲ្យតម្លៃទៅលើកិត្តិយស ទោះបីអស់ទ្រព្យអស់សម្បត្តិក៏ដោយ កុំឲ្យតែខូចកិត្តិយសខូចកេរ្តិ៍ឈ្មោះ ។ ស្វាមីភរិយាខ្មែរ ដែលបានគ្នាជាប្តីប្រពន្ធដោយម្តាយឪពុកទុកដាក់ មិនសូវឃើញលែងលះគ្នាឡើយ ឃើញតែរស់នៅជាមួយគ្នារហូតចាស់ជរា ។ វប្បធម៌ខ្មែរដ៏ល្អនេះបានត្រូវប្រទេសនៅអឺរ៉ុបកោតសរសើរយ៉ាងខ្លាំង ។

ចំពោះកូនចៅស្រីកម្មករខ្មែរដែលអត់ការងារធ្វើ ដោយរោងចក្របានបិទទ្វារ ត្រូវរកការងារធ្វើកន្លែងផ្សេងទៀត ។ គួររកការងារណាដែលឥតទោស ការងារដែលសង្គមឲ្យតម្លៃ ។ កុំឲ្យធ្លាក់ទៅលើការងារស្រីពេស្យាតាមការអូសទាញរបស់ឈ្មួញទុច្ចរិត និងជនខិលខូចឲ្យសោះ ។ ដូចបានពោលមកហើយ មុខរបរស្ត្រីពេស្យានេះជាមុខរបរមិនស្ថិតស្ថេរ សង្គមមិនឲ្យតម្លៃ អាចខូចសុខភាពអស់មួយជីវិត ។ ប្រទេសកម្ពុជាជាប្រទេសកសិកម្មចំនួនជាង៨០ភាគរយ ពីដើមឪពុកម្នាក់អាចចិញ្ចឹមកូន៩, ១០នាក់ ឲ្យរស់បានដោយការធ្វើស្រែចំការនេះឯង ។ បើរកការងារធ្វើដ៏ត្រឹមត្រូវនៅទីក្រុងមិនបានទេ កូនចៅគួរត្រឡប់ទៅធ្វើការងារកសិកម្មទៅភូមិកំណើតវិញជាការប្រសើរបំផុត កុំប្រកបមុខរបរណាដែ-

លនាំឲ្យខូចកិត្តិយសខ្លួននិងកិត្តិយសគ្រួសារ ។ ការកើតមកជាមនុស្ស ទោះជាបុរសក្តីស្ត្រីក្តីមានតម្លៃណាស់ កុំធ្វើឲ្យតម្លៃខ្លួនថោកទាប ។ ការកើតមកជាមនុស្សជាការក្រ បានកើតមកជាមនុស្សហើយ ធ្វើខ្លួនឲ្យទៅជាមនុស្សពេញលក្ខណៈជាការក្រ ។ យ៉ាងណាមិញ បណ្តាស្ត្រីទាំងឡាយក្នុងប្រទេសនៅអាស៊ីភាគអាគ្នេយ៍ គេសរសើរស្ត្រីខ្មែរថាមានចរិយាល្អ គោរពស្វាមី គោរពមាតាបិតា ហើយគេកម្រឃើញភរិយាក្បត់ចិត្តពីស្វាមីណាស់ មានតែបុរសខ្មែរទេ ដែលមានខ្លះក្បត់ចិត្តពីភរិយារបស់ខ្លួនទៅរកស្ត្រីដទៃទៀត ។ គេសង្កេតឃើញទៀតថាស្ត្រីខ្មែរពុំសូវយកបុរសបរទេសជាប្តីរបស់ខ្លួនឡើយ ។ ដូច្នេះកូនចៅកម្មករស្ត្រីខ្មែរ បើបាត់បង់ការងារក្នុងរោងចក្រហើយ កុំជឿការអូសទាញពីជនទុច្ចរិតឲ្យទៅប្រកបមុខរបរអបាយមុខ គឺមុខរបរពេស្យាចារ ឬទៅរកស៊ីនៅបរទេស គួរត្រឡប់មកជួបម្តាយឪពុកនៅភូមិកំណើតវិញ គួរការពារកិត្តិយសមាតាបិតា កុំឲ្យគាត់បាក់មុខបាក់មាត់ ធ្វើខ្លួនឲ្យទៅជាស្ត្រីរតនៈ ជាមាតានៃពិភពលោក ។៚

❊ ❊

❊